# សេចក្តីជូនដំណឹង

## ព្រះរាជាណាចក្រកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំកំពូល សម្ព័ន្ធប្រតិបត្តិករកម្មវិធីផ្តល់អាហារនៅសាលារៀនតំបន់អាស៊ីអគ្នេយ៍ ដើម្បីជំរុញការអភិវឌ្ឍមូលធនមនុស្ស និងបរិវត្តកម្មប្រព័ន្ធស្បៀងអាហារ

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤

រាជរដ្ឋាភិបាលកម្ពុជា ដោយមានកិច្ចសហការជាមួយរដ្ឋាភិបាលហ្វីលីពីន និងកូរ៉េខាងត្បូង នឹងទទួលរៀបចំកិច្ចប្រជុំកំពូលសម្ព័ន្ធប្រតិបត្តិករកម្មវិធីផ្តល់អាហារនៅសាលារៀនតំបន់អាស៊ីអគ្នេយ៍ ដើម្បីជំរុញការអភិវឌ្ឍមូលធនមនុស្ស និងបរិវត្តកម្មប្រព័ន្ធស្បៀងអាហារ ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី១៨-២០ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅក្រុងសៀមរាប។ កិច្ចប្រជុំកំពូលនេះ នឹងត្រូវរៀបចំក្រោមក្របខណ្ឌនៃសម្ព័ន្ធប្រតិបត្តិករកម្មវិធីផ្តល់អាហារនៅសាលារៀនសកល ហើយនឹងជាព្រឹត្តិការណ៍ដ៏សំខាន់មួយដែលបញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តពីបណ្តាប្រតិបត្តិករនៃកម្មវិធីផ្តល់អាហារនៅសាលារៀននៅក្នុងតំបន់ ក្នុងការជំរុញការអភិវឌ្ឍមូលធនមនុស្ស និងបរិវត្តកម្មប្រព័ន្ធស្បៀងអាហារ។

កិច្ចប្រជុំកំពូលនេះនឹងប្រព្រឹត្តទៅដោយមានការចូលរួម ពីតំណាងនៃស្ថាប័នពាក់ព័ន្ធជាន់ខ្ពស់ដែលអញ្ជើញមកពីបណ្តាប្រទេសក្នុងតំបន់អាស៊ីអគ្នេយ៍ ក៏ដូចជាតំណាងមកពីប្រទេសចិន ជប៉ុន និងកូរ៉េខាងត្បូង។ កិច្ចប្រជុំនេះ ជាសក្ខីកម្មនៃកាលានុវត្តភាពដ៏ចាំបាច់បំផុត ដែលស្ថាប័នពាក់ព័ន្ធទាំងអស់នៃបណ្តាប្រទេសក្នុងតំបន់អាស៊ីអគ្នេយ៍ នឹងត្រូវរួមសហការលើគោលនយោបាយ ដែលមានគោលដៅលើកកម្ពស់សុខភាព ការអប់រំ និងសក្តានុពលនាថ្ងៃអនាគតសម្រាប់កុមារ តាមរយៈនិរន្តរភាពនៃកម្មវិធីផ្តល់អាហារនៅសាលារៀន។ កិច្ចប្រជុំនេះ មានគោលបំណងធានាឱ្យបានកាន់ច្បាស់លាស់ថា កុមារនៅបណ្តាប្រទេសក្នុងតំបន់អាស៊ីអគ្នេយ៍និងតំបន់ផ្សេងៗទៀត នឹងទទួលបានអាហារនៅសាលារៀនប្រកបដោយអាហារូបត្ថម្ភខ្ពស់ និងសុខភាពប្រសើរ នៅត្រឹមបំណាច់ឆ្នាំ២០៣០។

នាពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តកម្មវិធីផ្តល់អាហារនៅសាលារៀនដោយប្រើកសិផលសហគមន៍ ដោយមានវិសាលភាពលើសាលាបឋមសិក្សាគោលដៅប្រមាណ២ភាគ៣ ជាមួយនិងការប្តេជ្ញាចិត្តក្នុងការសម្រេចបានការគ្រប់ដណ្តប់ផ្នែកថវិកាអនុវត្តកម្មវិធីឱ្យបានដល់សាលាបឋមសិក្សាចំនួន១១១៤ និងផ្តល់អាហារជូនដល់កុមារឱ្យបាន

៣០០ពាន់នាក់ នៅអំឡុងឆ្នាំ២០២៨។ កម្មវិធីនេះ ក៏បានអនុវត្តទន្ទឹមគ្នាជាមួយកម្មវិធីអាហារូបករណ៍ជាសាច់ប្រាក់ ដែលផ្តល់ជូនសិស្សានុសិស្សមកពីគ្រួសារក្រីក្រពីកម្រិតបឋមសិក្សាដល់មធ្យមសិក្សាទុតិយភូមិប្រមាណ៦៥ម៉ឺននាក់។ ប្រការនេះជាការធានាបាននូវការគាំពារផ្នែកអាហារូបត្ថម្ភសមរម្យ និងបរិស្ថានសៀងអាហារសមប្រកប ដែលអាចរក្សាប្រសិទ្ធភាពនៃដំណើរការលទ្ធកម្ម និងការចែកចាយស្បៀងអាហារ ការកសាងសមត្ថភាពស្ថាប័ន និងការធានានិរន្តរភាពនៃហិរញ្ញប្បទាន។

ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានលើកឡើងថា កិច្ចប្រជុំកំពូលសម្ព័ន្ធប្រតិបត្តិករកម្មវិធីផ្តល់អាហារនៅសាលារៀនតំបន់អាស៊ីអគ្នេយ៍ ជាវេទិកាដ៏ពិសេសមួយដែលរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ អាចប្រមូលផ្តុំគ្នាផ្លាស់ប្តូរឧត្តមានុវត្តន៍ និងបញ្ជាក់សារជាថ្មីនូវការប្តេជ្ញាចិត្តក្នុងការផ្តល់អាហារដែលប្រកបដោយអាហារូបត្ថម្ភដល់កុមារ ដែលជាការតម្កល់ភាពចាំបាច់នៃកម្មវិធីផ្តលើអាហារនៅសាលារៀន ជាឧបករណ៍មួយនៃកម្មវិធីជាតិគាំពារសង្គម។ កិច្ចប្រជុំនេះ នឹងគូសបញ្ជាក់ពីបំណងប្រាថ្នានៃកម្ពុជា ចំពោះការបណ្តុះមូលធនមនុស្ស ការជំរុញកំណើនសេដ្ឋកិច្ច និងការធានាសុខមាលភាពនៃកុមារ។

របៀបវារៈនៃកិច្ចប្រជុំកំពូលនេះនឹងរួមបញ្ចូលការពិភាក្សា លើការពង្រឹងគុណភាពនិងប្រសិទ្ធភាព ការកែលម្អក្របខណ្ឌគោលនយោបាយ ការធ្វើឱ្យប្រសើរឡើងនូវយន្តការហិរញ្ញប្បទាន និងការបំផុសកិច្ចសម្របសម្រួលអន្តរវិស័យ នៃការអនុវត្តកម្មវិធីផ្តល់អាហារ និងការគាំទ្រផ្នែកអាហារូបត្ថម្ភនៅសាលារៀន។

សម្រាប់ព័ត៌មានបន្ថែម និងសំណើកិច្ចសម្ភាសន៍ សូមទាក់ទងមកកាន់ក្រសួងអប់រំ យុវជន និងកីឡា តាមរយៈអ៊ីម៉ែល info@moeys.gov.kh ឬទូរសព្ទ +855(0)12625538 ។